**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០០៩ សរណន

ថ្ងៃ អង្គារ ៩រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

# សារាចរណែនាំ

## ស្តីពី

## ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍នៅទូទាំងប្រទេសនូវវិធានសុវត្ថិភាពទេសចរណ៍ដែលត្រូវបានធ្វើបច្ចុប្បន្នភាព ដូចខាងក្រោម៖

### ១. ការធានាសុវត្ថិភាពភ្ញៀវទេសចរ

- ត្រូវអនុវត្តឲ្យបានយ៉ាងខ្ជាប់ខ្ជួននូវវិធានការទាំងឡាយ ដែលបានដាក់ចេញដោយក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩
- ត្រូវអនុវត្តឲ្យបានម៉ត់ចត់វិធានការ "៣ ការពារ" គឺពាក់ម៉ាស់ លាងដៃ និងរក្សាគម្លាតសុវត្ថិភាព និងវិធានការ "៣ កុំ" គឺកុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំចូលទៅកន្លែងដែលបិទជិត និងកុំប៉ះពាល់គ្នា"
- ត្រូវរៀបចំខ្លោងទ្វារចូលសហគមន៍ ដើម្បីស្រង់ព័ត៌មានភ្ញៀវទេសចរទាំងអស់ដែលចូលកម្សាន្តក្នុងសហគមន៍ ជាពិសេសកត់ត្រាអាសយដ្ឋាន និងលេខទំនាក់ទំនងភ្ញៀវទេសចរឲ្យបានម៉ត់ចត់
- ត្រូវចុះឈ្មោះបង្កើត និងប្រើប្រាស់ប្រព័ន្ធ QR Code ទប់ស្កាត់កូវីដ-១៩ និងតម្រូវឲ្យភ្ញៀវទេសចរត្រូវតែស្កេនជាដាច់ខាត មុនចូលទៅក្នុងកន្លែងរបស់ខ្លួន
- ត្រូវរៀបចំនូវការត្រួតពិនិត្យកំដៅគ្រប់ភ្ញៀវទេសចរដែលត្រូវចូលទៅកម្សាន្តនៅតាមសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍
- ត្រូវរៀបចំឲ្យមានការបាញ់អាល់កុលសំលាប់មេរោគមុននឹងចូលកម្សាន្តក្នុងរមណីយដ្ឋាន
- ភ្ញៀវទេសចរតម្រូវឲ្យពាក់ម៉ាស់ និងលាងសំអាតដៃជាប្រចាំរាល់ពេលដែលចាប់កាន់វត្ថុថ្មី
- ត្រូវរៀបចំឲ្យមានសមាជិកប្រចាំការដើម្បីណែនាំភ្ញៀវទេសចរឱ្យអនុវត្តតាមវិធានសុវត្ថិភាពក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ មុនពេលចូលកម្សាន្តក្នុងសហគមន៍
- ត្រូវបញ្ចៀសការជួបជុំជាក្រុមធំ និងត្រូវរក្សាគំលាតសុវត្ថិភាពឲ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាល
- ត្រូវជំរុញលើកទឹកចិត្តភ្ញៀវទេសចរឲ្យទៅលំហែកម្សាន្តជាមួយធម្មជាតិ និងសក្តានុពលដែលមានក្នុងសហគមន៍ ដើម្បីបញ្ចៀសការជួបជុំទ្រង់ទ្រាយធំ
- ត្រូវខិតខំរៀបចំឲ្យមានលំហបើកទូលាយឲ្យបានច្រើនកន្លែងនៅក្នុងសហគមន៍។

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

## ២. ការរៀបចំសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

- ត្រូវកំណត់អំពីសមត្ថភាពផ្ទុកអតិបរមា (Carrying Capacity) ដែលសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ អាចទទួលភ្ញៀវទេសចរបានក្នុងមួយពេល
- ត្រូវកំណត់តំបន់ ឬទីតាំងក្នុងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ អាចប្រើប្រាស់រួមគ្នាបាន
- ត្រូវរៀបចំឱ្យមានអាល់កុលបាញ់សំលាប់មេរោគ និងសម្រាប់លាងដៃឱ្យបានគ្រប់គ្រាន់ និងគ្រប់ទីកន្លែងដែលចាំបាច់
- ត្រូវលើកស្លាកសញ្ញាស្តីពីគ្រោះថ្នាក់ និងវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ ឱ្យបានច្បាស់លាស់ និងគ្រប់គ្រាន់នៅតាមទីតាំងសំខាន់ៗក្នុងសហគមន៍
- ត្រូវបិទផ្សាយបណ្ណព័ត៌មាន និងសេចក្តីប្រកាសនានាអំពីវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងទេសចរណ៍ ក្នុងការទប់ស្កាត់ការរីករាលនៃជំងឺកូវីដ-១៩
- ត្រូវធ្វើការសំអាតឱ្យបានជាប្រចាំបន្ទប់ទឹក បរិវេណ និងទីតាំងនានា ដែលភ្ញៀវបានប៉ះពាល់
- សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ដែលផ្តល់សេវាស្នាក់នៅ ម្ហូបអាហារ និងសេវាផ្សេងៗជូនភ្ញៀវទេសចរ ត្រូវអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍នៃសេវាទាំងនោះ ដែលដាក់ចេញដោយក្រសួងទេសចរណ៍
- ខិតខំអនុវត្តការគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ក្នុង "គន្លងប្រក្រតីភាពថ្មី (New Normal Protocol)"
- ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តនូវគោលនយោបាយនានាក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសគាំទ្រដល់គោលនយោបាយចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែង

## ៣. ការបណ្តុះបណ្តាលបុគ្គលិក

- គ្រប់បុគ្គលិក និងសមាជិកបម្រើការក្នុងសហគមន៍ ត្រូវទទួលការចាក់វ៉ាក់សាំងគ្រប់ចំនួនដូសតាមការណែនាំរបស់ក្រសួងសុខាភិបាល
- គ្រប់បុគ្គលិក និងសមាជិកបម្រើការក្នុងសហគមន៍ ត្រូវទទួលបានការបណ្តុះបណ្តាលអំពីវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- គ្រប់បុគ្គលិក និងសមាជិកបម្រើការក្នុងសហគមន៍ ត្រូវទទួលបានការបណ្តុះបណ្តាលអំពីសេវាកម្មទេសចរណ៍ និងការធ្វើបដិសណ្ឋារកិច្ចប្រកបដោយស្តង់ដា
- គ្រប់បុគ្គលិក និងសមាជិកបម្រើការក្នុងសហគមន៍ ត្រូវអនុវត្តជាគំរូ និងជាប្រចាំក្នុងពេលបំពេញការងារនូវរាល់វិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- គ្រប់បុគ្គលិក និងសមាជិកបម្រើការក្នុងសហគមន៍ ត្រូវពន្យល់ណែនាំអំពីវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ទៅដល់ភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធ និងតម្រូវឱ្យភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធចូលរួមអនុវត្តជាកាតព្វកិច្ច។ ក្នុងករណីភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធពុំអនុវត្តតាម ត្រូវរាយការណ៍ទៅគណៈគ្រប់គ្រងសហគមន៍ ដើម្បីមានវិធានការបន្ត

- សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ត្រូវលើកទឹកចិត្តឲ្យសមាជិក និងបុគ្គលិកទាំងអស់រាយការណ៍អំពីស្ថានភាពសុខភាពជាប្រចាំដើម្បីបញ្ចៀសហានិភ័យនៃការចំលងជំងឺកូវីដ-១៩ ជាយថាហេតុ។

មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ចុះណែនាំដល់គ្រប់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ដើម្បីអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដែលត្រូវបានធ្វើបច្ចុប្បន្នភាពនេះជាកាតព្វកិច្ច ឲ្យមានប្រសិទ្ធភាពខ្ពស់ក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ករណីដែលសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ណាខកខានមិនបានអនុវត្តតាមសារាចរណែនាំនេះ មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការផ្អាកសកម្មភាពទេសចរណ៍ និងអេកូទេសចរណ៍របស់សហគមន៍នោះ រហូតអនុវត្តបានត្រឹមត្រូវតាមខ្លឹមសារសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ មន្ទីរទេសចរណ៍រាជធានី ខេត្ត និងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍នៅទូទាំងប្រទេស ត្រូវទទួលអនុវត្តឲ្យមានប្រសិទ្ធភាព ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- គ្រប់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ទូទាំងប្រទេស
- ឯកសារ កាលប្បវត្តិ